# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/០១០១/០១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

===

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១. ១២. ១៣. ១៨. ២២. ២៤. ២៦. ២៨. ៣០. ៣៤. ៥១. ៩០. ៩១. ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសាជីវកម្ម អាហ័រណេ នីហ័រណេ បច្ចេកវិទ្យាថាមពលអគ្គិសនី ចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០០

នាសម័យប្រជុំពេញអង្គលើទី៥ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី១ ហើយដែលមាន សេចក្ដីទាំងស្រុងដូចតទៅ :

## ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល កម្ពុជា ឱ្យសាជីវកម្ម អាហារ័ណ នីហារ័ណ បច្ចេកវិទ្យា ថាមពល អគ្គិសនី ចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនអគ្គិសនីកម្ពុជា អោយសាជីវកម្ម អាហារ័ណ នីហារ័ណ បច្ចេកវិទ្យា ថាមពល អគ្គិសនី ចិន ហៅ "សេទិច" ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគំរោងរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនសេទិច និងកិច្ចព្រមព្រៀងទិញអគ្គិសនីរវាងក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុន សេទិច ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០០ ។ ការធានានេះមានអត្ថបទ ទាំងស្រុងដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០០ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលកម្ពុជាភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតធានាលើការទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

===

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទូរស័ព្ទ/ទូរសារ : ០២៣ ៤២៧៧៩៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០០

## ការធានានូវធានារបស់រដ្ឋាភិបាល

ជូនចំពោះ : សាជីវកម្ម អាហរ័ណ នីហរ័ណ បច្ចេកវិទ្យា ថាមពល អគ្គិសនី ចិន

(China Electric Power Technology Import & Export Corp.)
Block N° 5, Lipukang Street, West district
Beijing, P.R. China

យោងតាមកិច្ចព្រមព្រៀងជាវថាមពល (ដូចដែលបានធ្វើវិសោធនកម្ម កែប្រែ បន្ថែម ឬ ធ្វើការផ្ទេរនៅពេលណាមួយ, ហៅថា “PPA”) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០០ ធ្វើឡើងដោយ និងរវាងសាជីវកម្ម អាហរ័ណ នីហរ័ណ បច្ចេកវិទ្យា ថាមពល អគ្គិសនី ចិន (CETIC) ដែលជាក្រុមហ៊ុនមួយបានបង្កើត

ឡើងតាមច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិន ដែលមានការិយាល័យស្របច្បាប់ស្ថិតនៅ Block N0 5, Lipukang Street, West district, Beijing, P.R.China រួមទាំងក្រុមហ៊ុនអនុវត្តគំរោង ដែលបានបង្កើតឡើងដោយ CETIC ក្នុងគោលបំណងអនុវត្តកិច្ចព្រមព្រៀងជាវថាមពល និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធផ្សេងៗទៀត អ្នកបន្តវេន និងអ្នកចាត់តាំងដែលមានការអនុញ្ញាត ( CETIC និងក្រុមហ៊ុនអនុវត្តគំរោងក្នុងករណីដែលមាន និងបន្ទាប់មកក្នុងនេះរួមគ្នាហៅថា "ក្រុមហ៊ុន") និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ដែលជាសហគ្រាសរដ្ឋទទួលខុស ត្រូវមានកំណត់ហើយដែលបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានទីស្នាក់ការកណ្ដាលស្ថិតនៅវិថីព្រះយុគន្ធរ (វត្តភ្នំ) ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រួមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិរបស់គេ (ពីនេះទៅមុខហៅថា "EDC") និងកិច្ចព្រមព្រៀងអនុវត្ត (ដែលបានធ្វើវិសោធនកម្ម កែប្រែ បន្ថែម ឬ ផ្ទេរនៅពេលណាមួយហៅថា "IA") ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០០ ដែលបានធ្វើឡើង និងចុះហត្ថលេខា ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) និងក្រុមហ៊ុនក្នុងគោលបំណង ភារកិច្ចអគ្គិសនី គីរីរម្យទី១

ដោយហេតុថា IA ទាមទារថា : (i) MIME ត្រូវធ្វើយ៉ាងណាដើម្បីអោយក្រុមហ៊ុនទទួលបាននូវលិខិតធានាការទូទាត់នូវចំនួនដែលត្រូវទូទាត់ឱ្យក្រុមហ៊ុនស្របតាម IA និង PPA ហើយលិខិតធានាការទូទាត់នេះ ត្រូវចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលកម្ពុជា (ii) MIME ត្រូវធ្វើយ៉ាងណាដើម្បីអោយលិខិតធានាការទូទាត់បានចេញអោយនោះ ស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាអោយលិខិតធានានោះមានសុពលភាព និងអាចអនុវត្តបាន នៅពេលចេញ និងគ្រប់ពេលតមកទៀតក្នុងអាណត្តិនៃលិខិតធានានេះ

យើងខ្ញុំសូមផ្ដល់ជូននូវលិខិតធានាលើការទូទាត់របស់រដ្ឋាភិបាលនេះ និងសូមធានាថានឹងធ្វើការទូទាត់ជូនលោកដោយអនុលោមទៅតាមលិខិតធានានេះនូវទឹកប្រាក់ណាមួយ នៅពេលដែលយើងខ្ញុំបានទទួលវិក្កយបត្រទាររបស់លោកជាលាយលក្ខអក្សរតាមគំរូដែលមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ "ក" នៃលិខិតធានានេះក្នុងករណីដែលអាចមាន ។

ដូច្នេះយើងខ្ញុំសូមធានាដូចខាងក្រោម :

១- ក្នុងរយពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបាននូវសំណើរបស់ក្រុមហ៊ុន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការទូទាត់អោយក្រុមហ៊ុននូវទឹកប្រាក់ទាំងអស់ និងបំពេញនូវកាតព្វកិច្ច

និងការទទួលខុសត្រូវទាំងអស់ ទោះជាមានជាក់ស្តែង ឬកើតឡើងបច្ចុប្បន្ន ឬកើតទៅពេលអនាគតក្តី លើប្រាក់ជំពាក់របស់ MIME ឬ EDC ក្នុងការបំពេញកាតព្វកិច្ចតាម PPAឬIA ដោយគិតបញ្ចូលទាំងកាតព្វកិច្ចទាំងអស់របស់ MIME ឬ EDC ទាក់ទងទៅនឹងការទូទាត់ទាំងអស់តាម PPA និង IA បូកជាមួយការប្រាក់ ដែលកើតមានឡើងចាប់ពីថ្ងៃដែលជំពាក់រហូតដល់ថ្ងៃសង លើទឹកប្រាក់ទាំងអស់ដែលជាកាតព្វកិច្ច និងការទទួលខុសត្រូវ ដែលបានធានាតាមអត្រា និងតាមលក្ខខណ្ឌដែលត្រូវទូទាត់អោយក្រុមហ៊ុន ដោយអនុលោមទៅតាម PPA និង IA និងការពិន័យផ្សេងៗទៀតស្របតាមច្បាប់កម្ពុជាដែលមានជាធរមាន ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមព្រៀងថានឹងចេញសងក្រុមហ៊ុនអោយបានពេញលេញលើរាល់ការខូចខាត ការខាតបង់ និងការចំណាយដែលកើតមានឡើងពីការខកខានមិនបានបំពេញកាតព្វកិច្ច ឬការទទួលខុសត្រូវណាមួយរបស់ MIME និង/ឬ EDC តាម PPA និង IA ។

២- ទឹកប្រាក់ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវទូទាត់អោយតាមការធានានេះ ត្រូវបង់បញ្ចូលទៅក្នុងគណនីធនាគារ ដែលក្រុមហ៊ុនបានកំណត់ និងបង់ជារូបិយវត្ថុដែលក្រុមហ៊ុនអាចទទួលយកបាន និងលើកលែងពន្ធបច្ចុប្បន្ន និងពន្ធ ឬ អាករ នាពេលអនាគតទាំងអស់ និងមិនត្រូវទាមទារ ឬ តវ៉ា ឬ ដាក់លក្ខខណ្ឌណាមួយលើចំនួនទឹកប្រាក់អតិបរមា ដែលច្បាប់កម្ពុជាបានអនុញ្ញាតិនោះឡើយ ។ ប្រសិនបើច្បាប់បង្ខំអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការកាត់បន្ថយ ឬកាត់ទុកនូវទឹកប្រាក់ណាមួយនោះ ក្រសួងត្រូវទូទាត់ភ្លាមទៅអោយក្រុមហ៊ុននូវទឹកប្រាក់បន្ថែម ដើម្បីធ្វើយ៉ាងណាអោយក្រុមហ៊ុនបានទទួលទឹកប្រាក់សុទ្ធនោះស្មើនឹងចំនួនពេញលេញ ដែលក្រុមហ៊ុនត្រូវទទួលបាន ដោយមិនមានការកាត់កងឬកាត់ទុកអ្វីឡើយ ។

៣- លិខិតធានានេះ គឺជាការធានារ៉ាប់រងអចិន្ត្រៃយ៍ និងត្រូវធានាលើតុល្យភាពពិតប្រាកដលើទឹកប្រាក់ ដែលជំពាក់ក្រុមហ៊ុនដោយ MIME និង/ឬ EDC តាមលក្ខណៈណាមួយដែលគណនាតាម IA និង PPA ទោះជាមានលិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ឬការរំលាយ ឬ អសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ទាក់ទងទៅនឹង MIME និង/ឬ EDC ក្នុងនាម ឬ របៀប ឬការទូទាត់គណនី ឬបញ្ហានាមួយក៏ដោយ ។

៤- លិខិតធានានេះ មិនត្រូវបញ្ចូលជាមួយ ឬធ្វើឱ្យខូចខាត ឬ ប៉ះពាល់ទៅលើសិទ្ធិណាមួយផ្សេងទៀតក្នុងការចេញសង ការធានា ការទទួលខុសត្រូវដែលក្រុមហ៊ុនអាចមានតាម IA និង PPA កិច្ចព្រមព្រៀងរបស់គំរោងផ្សេងៗទៀត និងតាមច្បាប់ជាធរមានរបស់កម្ពុជា ។

៥- មិនយកការខកខាន ការយឺតយ៉ាវរបស់ក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការចេញសងរបស់ក្រុមហ៊ុនជាមូលហេតុ ដើម្បីជាការបដិសេធនូវអ្វីៗដែលមានទាំងការអនុវត្តន៍ចំណុចណាមួយ ឬផ្នែកណាមួយ ឬការបដិសេធសិទ្ធិណាមួយ ឬការចេញសងណាមួយ ដែលនឹងទប់ស្កាត់នូវការអនុវត្តន៍បន្ថែម ឬការអនុវត្តន៍សិទ្ធិណាមួយ ឬការចេញសងណាមួយផ្សេងនៅពេលក្រោយទៀត ។

៦- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានព្រមព្រៀងដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការកែក្រឡាស់ថា ការអនុវត្តន៍ និងការទូទាត់ដោយក្រសួងតាមលិខិតធានានេះ គឺជាសកម្មភាពជាឯកជន និងពាណិជ្ជកម្មមិនមែនជាសកម្មភាពជាសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ គឺជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចកែក្រឡាស់បានឡើយ ។ មិនមានការកែប្រែចំពោះលក្ខខណ្ឌនៃ PPA ឬចំពោះភាគីក្នុងកិច្ចព្រមព្រៀងនេះ ឬចំពោះខ្លឹមសារ ឬលក្ខណៈនៃកាតព្វកិច្ច ដែលត្រូវអនុវត្តដោយក្រុមហ៊ុន តាមកិច្ចព្រមព្រៀងទាំងនោះ ឬការបញ្ចប់កិច្ចព្រមព្រៀងណាមួយ ដោយអនុលោមទៅតាមលក្ខខណ្ឌរបស់វា ហើយដែលលោកមិនបានផ្តល់ពេលវេលា ឬការហាមឃាត់ ឬការអនុគ្រោះណាមួយដែលអាចលើកលែងអោយយើងរួចផុតពីកាតព្វកិច្ចព្រមព្រៀងនោះ អាចលើកលែងអោយយើងរួចផុតពីការទទួលខុសត្រូវណាមួយក្នុងនេះ និងអាចដំណើរការក្តីប្រឆាំងនឹងក្រុមហ៊ុន ឬទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន (ក្រៅពីទ្រព្យសម្បត្តិលើកលែង) ក្នុងយុត្តាធិការណាមួយដែលទាក់ទងនឹង IA, PPA និងលិខិតធានានេះ ហើយមិនមានអភ័យឯកសិទ្ធិណាមួយក្នុងដំណើរការក្តីដែលត្រូវតវ៉ាតាងនាមខ្លួនឯង និងតាងនាមក្រុមហ៊ុន ទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន (ក្រៅពីទ្រព្យសម្បត្តិលើកលែង) ដែលមានបច្ចុប្បន្ន ឬមាននាពេលអនាគត ។

៧- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការអះអាងថា ក្រសួងមានសិទ្ធិអំណាចពេញលេញក្នុងការចុះហត្ថលេខាលើលិខិតធានា និងបំពេញកាតព្វកិច្ចដែលមានតាមលិខិតធានានេះ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិដំណើរការតាមគោលការណ៍តាមការសំរេចរបស់ខ្លួនផ្ទាល់ពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងលក្ខខណ្ឌ និងសិទ្ធិទាំងឡាយ និងកាតព្វកិច្ចទាំងឡាយនៃភាគី

ទាំងអស់ ដែលលក្ខខណ្ឌក្នុងនេះរក្សាដដែលគ្មានការកែប្រែ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់សុពលភាពដល់លិខិតធានានេះ រួចលិខិតធានានេះនឹងមានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងកាតព្វកិច្ចតាមផ្លូវច្បាប់លើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវអនុវត្តអនុលោមតាមលក្ខខណ្ឌរបស់វា ។ ការរៀបចំ និងការអនុវត្តន៏លិខិតធានានេះមិនមានផ្ទុយទៅនឹងច្បាប់ដែលមាន ឬការវិនិច្ឆ័យជាធរមានណាមួយ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងជាប់ពាក់ព័ន្ធឡើយ នឹងមិនមានប៉ះពាល់ផលប្រយោជន៏ ឬបំពានទៅលើលក្ខខណ្ឌ ឬធ្វើអោយមានកំហុសតាមកិច្ចព្រមព្រៀងណាមួយដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាភាគី ឬដែលត្រូវគោរពតាម ឬដែលមានប្រសិទ្ធភាពទៅលើទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ។

៨- ប្រសិនបើមានវិវាទ ឬមានភាពខុសគ្នាណាមួយកើតឡើង ឬពាក់ព័ន្ធទៅនឹងលិខិតធានានេះ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីភាគីមួយបានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីខ្លឹមសារនៃវិវាទនោះ ហើយភាគីទាំងអស់ត្រូវដោះស្រាយវិវាទនោះតាមរយៈការពិភាក្សាដោយមិត្តភាព ។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាដោយមិត្តភាពទេ គេត្រូវដាក់វិវាទនោះទៅដោះស្រាយនៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសឹង្ហបុរី ដើម្បីដោះស្រាយស្របទៅតាមវិធាននៃមជ្ឈមណ្ឌលកាត់ក្តីអន្តរជាតិសឹង្ហបុរីនោះ ។ ប្រសិនបើមានភាពខុសគ្នាដោយអន្លើរវាងមាត្រានេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសឹង្ហបុរីនោះមាត្រានេះត្រូវមានប្រសិទ្ធភាព ។ សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខអក្សរហើយ គឺជាសេចក្តីសំរេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើភាគីទាំងអស់ និងអាចមានយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាដែលមានយុត្តាធិការអនុវត្តសេចក្តីសំរេចនោះបាន ។ ភាគីទាំងនោះត្រូវអនុវត្តតាមសេចក្តីសំរេចនោះ ហើយភាគីនីមួយៗ មិនអាចបដិសេធដោយកែក្រឡាស់ទៅលើសិទ្ធិដែលគេមាន ដើម្បីតវ៉ាទៅលើសុពលភាពនៃសេចក្តីសំរេចនេះ ឬទៅលើយុត្តាធិការនៃសាលាកាត់ក្តីដែលត្រូវដំណើរការក្តីលើលិខិតធានានេះទេ ។ ការទូទាត់តាមសេចក្តីសំរេចរបស់ការកាត់ក្តី ត្រូវធ្វើឡើងជាដុល្លារអាមេរិក ។ ចំណាយលើការកាត់ក្តីត្រូវចេញដោយភាគីដែលចាញ់ក្តី លើកលែងតែមានកំណត់ផ្សេងពីនេះដោយមជ្ឈមណ្ឌលកាត់ក្តីនោះ ។ ភាគីដែលទទួលខុសត្រូវការទូទាត់តាមសេចក្តីសំរេចរបស់ការកាត់ក្តី ត្រូវបង់ការប្រាក់តាមអត្រា ១២ ភាគរយទៅអោយភាគីដែលទទួលសេចក្តីទទួលសេចក្តីសំរេចពីការកាត់ក្តីនោះ ចាប់ពីកាលបរិច្ឆេទជំពាក់ការទូទាត់ តាមសេចក្តីសំរេចរហូតដល់ថ្ងៃទូទាត់ ។

៩- សិទ្ធ និងកាតព្វកិច្ចរបស់ភាគីទាំងអស់ដែលមាននៅក្រោម និងអនុលោមទៅតាមលិខិតធានានេះ ត្រូវបានគ្រប់គ្រង និងបកស្រាយលើរាល់ទិដ្ឋភាពទាំងអស់ ដោយផ្អែកលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីដែលច្បាប់កម្ពុជាពុំអាចបកស្រាយបានទេនោះ ច្បាប់អង់គ្លេសនឹងត្រូវបានយកមកអនុវត្ត ។

១០- កាតព្វកិច្ចរបស់យើងខ្ញុំក្នុងលិខិតធានានេះនឹងមានប្រសិទ្ធភាពពេញលេញ ក្រោយពីការពិនិត្យ និងផ្តល់សច្ចាប័នដោយ រដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកាតព្វកិច្ចបំពេញការងារនេះ ដើម្បីទទួលបានការផ្តល់សច្ចាប័នក្នុងរយៈពេល១ខែ បន្ទាប់ពី IA និង PPA ចូលជាធរមាន ។ លិខិតធានានេះត្រូវផុតកំណត់ដូចគ្នាជាមួយការបញ្ចប់ IA និង PPA ដែរ ប្រសិនបើគ្មានការតវ៉ា និងនៅរក្សាការធានាតាមនេះដដែល និងគ្មានការស្នើសុំជាលាយលក្ខអក្សរណាមួយពីលោកមកយើងខ្ញុំពីបញ្ហានេះ ដែលយើងខ្ញុំត្រូវទទួលឱ្យបានមុនពេលផុតកំណត់នេះ ។

ដោយស្មោះស្ម័គ្រអំពីខ្ញុំ

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

====